**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សា**
**កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌**
**អង្គភាពគ្រប់គ្រងគម្រោង**

លេខៈ ០៣១/០៨ កហ អ.គ.គ

*រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែធ្នូ ឆ្នាំ២០០៨*

**កំណត់ហេតុ ស្តីពី ការជ្រើសរើសមន្ត្រីបង្គោល សម្រាប់ធ្វើការទំនាក់ទំនងពីការកែទម្រង់ច្បាប់ និងតុលាការ សិក្ខាសាលា ខេត្តសៀមរាប**

ឆ្នាំពីរពាន់ប្រាំបី ខែ តុលា ថ្ងៃទី ម្ភៃប្រាំបី វេលាម៉ោងប្រាំបីព្រឹក នៅសណ្ឋាគារនគរភ្នំ ខេត្តសៀមរាប មានរៀបចំ សិក្ខាសាលាមួយក្រោមអធិបតីភាពឯកឧត្តម សួង លាងហៃ ទីប្រឹក្សាទីស្តីការគណៈរដ្ឋមន្ត្រី និងជា នាយករងអង្គភាពគ្រប់គ្រងគម្រោងនៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដើម្បីធ្វើការពិភាក្សាជ្រើសរើស មន្ត្រី បង្គោលសម្រាប់ធ្វើទំនាក់ទំនងពីការកែទម្រង់ច្បាប់ និងតុលាការ ក៏ដូចជាការផ្សព្វផ្សាយកម្មវិធីសកម្មភាពសម្រាប់ អនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការដែលគណៈរដ្ឋមន្ត្រីបានអនុម័ត កាលពីថ្ងៃទី ២៩ ខែមេសា ឆ្នាំ ២០០៥ ។

សមាសភាពអ្នកចូលរួមប្រជុំមានដូចបញ្ជីជូនភ្ជាប់ជាមួយ ។

ជាកិច្ចចាប់ផ្តើមឯកឧត្តម សួង លាងហៃ បានធ្វើបទអន្តរាគមន៍ជម្រាបជូនអង្គសិក្ខាសាលាអំពីកំណទម្រង់ ទាំងបួនរបស់រាជរដ្ឋាភិបាល ដែលជាស្នូលនៃយុទ្ធសាស្ត្រចតុកោណ គឺកំណែទម្រង់រដ្ឋបាលសាធារណៈ កំណែទម្រង់ កម្លាំងប្រដាប់អាវុធ កំណែទម្រង់ច្បាប់ និងតុលាការ និងការប្រយុទ្ធប្រឆាំងអំពើពុករលួយ ។ ជាមួយគ្នានោះ ឯកឧត្តម បានជម្រាបជូនថា យើងធ្វើកំណែទម្រង់ទាំងបួនយ៉ាងនេះក្នុងគោលដៅរួមមួយគឺ អភិបាលកិច្ចល្អ ហើយឯកឧត្តម បានបញ្ជាក់ទៀតថា បើយើងពង្រឹងអភិបាលកិច្ចបានល្អនោះ ប្រទេសជាតិយើងនឹងមានការអភិវឌ្ឍន៍រីកចំរើនទៅមុខ យ៉ាងលឿន ។ រាជរដ្ឋាភិបាលបានអនុម័តនូវកម្មវិធីសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រ កំណែទម្រង់ច្បាប់ និង តុលាការ នៅថ្ងៃទី ២៩ ខែមេសា ឆ្នាំ ២០០៥ ។ កម្មវិធីសកម្មភាពនេះសម្រាប់មាន៩៧សកម្មភាព ដែលចែកចេញជាបី ដំណាក់កាល គឺសកម្មភាពរយៈពេលខ្លី សម្មភាពរយៈពេលមធ្យម និងសកម្មភាពរយៈពេលវែង ។ ឯកឧត្តមបានបញ្ជាក់ ជូនអំពីលទ្ធផលនៃការអនុវត្តសកម្មភាពទាំង៩៧នោះថា រហូតមកទល់ពេលនេះ យើងសម្រេចបានប្រមាណ ៦៨ ភាគរយ ក្នុងនោះក្រុមប្រឹក្សាដោះស្រាយបាននូវបញ្ហាកង្វះខាតចៅក្រម និងព្រះរាជអាជ្ញា ដោយការជ្រើសរើស បណ្តុះបណ្តាលចៅក្រមបន្ថែម ការបណ្តុះបណ្តាលក្រឡាបញ្ជីការបណ្តុះបណ្តាលចៅក្រមសម្រាប់វិវាទពាណិជ្ជកម្ម (ដែលជាបឋមត្រូវជ្រើសរើសចំនួន ១២នាក់ ពីចៅក្រមវិជ្ជាជីវៈសព្វថ្ងៃ ) ការបណ្តុះបណ្តាលអាជ្ញាសាលា

និងមេធាវី ជាដើម ។ ដោយឡែកគំរោងតុលាការគំរូ ដែលសព្វថ្ងៃនេះអនុវត្តនៅ៤ខេត្ត-ក្រុង កំពុងតែមានដំណើរការទៅមុខយ៉ាង សកម្មឧបត្ថម្ភដោយអង្គការ AusAid តាមរយ:អង្គការ CCJAPIII, DIHR &DANIDA ។ ចំពោះយន្តការដោះស្រាយវិវាទ ក្រៅប្រព័ន្ធតុលាការវិញ គម្រោងត្រូវបានអនុវត្តដោយក្រសួងយុត្តិធម៌ និងក្រសួងមហាផ្ទៃ ដែលកំពុងអនុវត្តនាពេល បច្ចុប្បន្ន ហើយនៅខេត្តសៀមរាបក៏មានគម្រោងនេះដែរ ដែលបានទទួលការឧបត្ថម្ភដោយអង្គការ UNDP ។ ឯកឧត្តម បានបញ្ជាក់ថា ឥឡូវនេះយើងចូលដល់ដំណាក់កាលនៃការតាមដានការអនុវត្តហើយ ។ ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ បាននឹងកំពុងរៀបចំប្រព័ន្ធសូចនាករតាមដាន និងវាស់វែង លទ្ធផលនៃការអនុវត្តគម្រោង ដែល ជាឧបករណ៍តាមដាន និងវាយតម្លៃភាពជឿនលឿននៃការអនុវត្តគម្រោងឬកម្មវិធីណាមួយសម្រាប់ស្វែងរកចន្លោះ ប្រហោងដែលត្រូវកែលំអ ។ ឯកឧត្តមប្រធានបានជម្រាបជូនថា គឺតាមរយ:ឧបករណ៍នេះដែលក្រុមប្រឹក្សាកំណែ ទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ អាចវាយតម្លៃបានថា ផែនការសកម្មភាពនៃការកែទម្រង់ច្បាប់របស់យើង ដែលបានធ្វើ តាំងពីឆ្នាំ ២០០៣ រហូតមកទល់ពេលនេះបានសម្រេចលទ្ធផលប្រមាណ ៦៨ភាគរយទៅនោះ ។ ដំណាក់កាលនៃការ តាមដានការអនុវត្ត ជាដំណាក់កាលសំខាន់ណាស់សំរាប់ការពិនិត្យមើលឡើងវិញនូវការអនុវត្តគម្រោង ហេតុដូច្នេះ ហើយ បានជាយើងរៀបចំអង្គសិក្ខាសាលានេះឡើង គឺដើម្បីជម្រាបជូនអង្គសិក្ខាសាលាអោយបានដឹងពីលទ្ធផល ដែល យើងសំរេចបាន និងអោយជួយតាមដានជាបន្តនូវការអនុវត្តទៅមុខទៀត ដោយនាំគ្នាពិភាក្សា ។ ជ្រើសរើសមន្ត្រី បង្គោលទំនាក់ទំនងកែទម្រង់ច្បាប់ និងតុលាការ ដើម្បីប្រមូលព័ត៌មាន ឬការចែករំលែកព័ត៌មានទាក់ទង និងការកែ ទម្រង់នេះ ។

ឯកឧត្តម ប៉ែន ប៊ុនឈា នាយករងអង្គភាពគ្រប់គ្រងគម្រោងបានធ្វើការបង្ហាញ ពីដំណើរការនៃការកែទម្រង់ ច្បាប់ និងតុលាការ ។ ឯកឧត្តមបានលើកឡើងពីរចនាសម្ព័ន្ធនៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រពន្ធ័យុត្តិធម៌ ក.ក.ច.ន.យ) ដែលបានបង្កើតឡើង នៅថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០២ ដោយមានឯកឧត្តម សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទីស្តីការគណ:រដ្ឋមន្ត្រី និងឯកឧត្តម ឌិត មុន្ទី ប្រធានតុលាការកំពូល សហប្រធាន (ក.ក.ច.ន.យ) បន្ទាប់មក ឯកឧត្តមបានជម្រាបជូនអង្គប្រជុំអំពីអង្គភាពនៅក្រោមឱវាទរបស់ក្រុមប្រឹក្សា ៖

- អង្គភាពសម្របសម្រួលអចិន្ត្រៃយ៍(អ.ស.ស)ដែលបានបង្កើតឡើងនៅថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០០២ ធ្វើជាសេនាធិការរបស់ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រពន្ធ័យុត្តិធម៌ ។
- អង្គភាពគ្រប់គ្រងគម្រោង (អ.គ.គ)ដែលបានបង្កើតឡើងនៅថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០០២ ដើម្បី ជួយអង្គភាពសម្របសម្រួលអចិន្ត្រៃយ៍ ក្នុងការបំពេញតួនាទីជាសេនាធិការ ។

ជាបន្ទាប់ឯកឧត្តមបានធ្វើការបង្ហាញអំពីកម្មវិធីសកម្មភាព ដែលមានក្នុងឯកសារសម្រាប់អនុវត្ត យុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការ ដែលមានចែកជូនជាឯកសារស្រាប់ដល់អង្គសិក្ខាសាលានាពេលនោះ ព្រមទាំងធ្វើការ ពន្យល់ផែនការសកម្មភាពនីមួយៗ និងបានដកស្រង់យកចំណុចសំខាន់ៗខ្លះ នៃឯកសារមកធ្វើអត្ថាធិប្បាយជូន

អង្គសិក្ខាសាលាដូចជា បញ្ហាប្រឈមមុខដែលត្រូវដោះស្រាយជាបន្ទាន់ដែលមានចែងក្នុងកម្មវិធីសកម្មភាពគឺ បញ្ហាទប់ស្កាត់អំពើពុករលួយក្នុងតុលាការ និងការកកស្ទះសំណុំរឿងនៅក្នុងតុលាការ មានជាអាទ៍៖

- ការជួលបន្ទប់សវនាការ
- ការខ្វះខាតចៅក្រម ក្រឡាបញ្ជី មេធាវី ជាដើម
- បញ្ហាដឹកជញ្ជូនជនជាប់ចោទពីពន្ធនាគារចូលសវនាការ
- ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ និងមណ្ឌលសេវាកម្មយុត្តិធម៌ ។

ជាមួយគ្នានេះឯកឧត្តមបាន លើកឡើងពីការបង្កើតមណ្ឌលសេវាកម្មថ្នាក់ស្រុកកន្លងមក ដែលមាន២០
ស្រុកក្នុងខេត្តទាំង៨ ហើយបច្ចុប្បន្ននេះ យើងបានពង្រីកមកដល់ខេត្តរតនៈគិរី និងខេត្តសៀមរាបទៀតផង ។

ជាបន្ទាប់គឺជាវេទិកាសំណួរ-ចម្លើយ ។

តំណាងខុទ្ទកាល័យសាលាខេត្តសៀមរាប បានមានមតិស្វាគមន៍ចំពោះបទបង្ហាញរបស់ឯកឧត្តម ប៉ែនប៊ុនឈា និងមានការចាប់អារម្មណ៍ខ្លាំងចំពោះការបង្កើតឡើងនូវការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ក្នុងបទល្មើសលហុនេះជាដើម ដែលជាការប្រសើរបំផុត ព្រោះអាចជួយដោះស្រាយបញ្ហាកកស្ទះសំណុំរឿងបាន ។ លោកបានជម្រាប់ផងដែរថា តុលាការសៀមរាបសព្វថ្ងៃនេះមានការងារច្រើនសម្រាប់ធ្វើដោយគ្របដណ្តប់ទៅលើខេត្ត ឧត្តរមានជ័យទៀតផង ។ ក្នុងនោះលោកបានជម្រាប់បន្ថែមទៀតថា សព្វថ្ងៃនេះបទល្មើសថ្នាក់លហុកាន់តែកើន ច្រើនឡើងៗ ។

ព្រះរាជអាជ្ញាខេត្ត បានមានប្រសាសន៍ថា បញ្ហាដែលនាយកខុទ្ទកាល័យបានលើកឡើងខាងលើនេះធ្វើអោយ លោកចាប់អារម្មណ៍ដែរ ទាក់ទងទៅនឹងបទល្មើសលហុនេះ លោកយល់ថា បទល្មើសលហុខ្លះក៏ជាបទព្រហ្មទណ្ឌដែរ ដូច្នេះ ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការមិនអាចធ្វើទៅរួចទេ គឺដោះស្រាយបានតែរឿងរដ្ឋប្បវេណី និងរឿង តូចតាចតែប៉ុណ្ណោះ ។ ចំពោះសំណុំរឿងចាស់ៗ មានព្រហ្មទណ្ឌ និងរដ្ឋប្បវេណីមិនមានការស្មុគ្រស្មាញទៀតទេ ប៉ុន្តែចំពោះរឿងវិវាទដីធ្លីនៅមានបញ្ហាច្រើន ។

លោក Ben Schultz ទីប្រឹក្សា CCJAPIII បានចូលរួមធ្វើបទអន្តរាគមន៍ក្នុងសិក្ខាសាលានោះដែរ លោកបាន មានប្រសាសន៍ថា យើងបានធ្វើការជាមួយសង្គមស៊ីវិល ពន្ធនាគារ ប៉ូលីស និងតុលាការ តាំងពីឆ្នាំ ១៩៩៧ ។ ហើយលោកបានលើកយកចំណុចមួយដែលនៅមានការខ្វះខាត គឺនៅតាមថ្នាក់ខេត្តមិនទាន់មានលក្ខណៈសម្របសម្រួលនៅឡើយទេ ។ នៅតាមខេត្តយើងមានគណៈកម្មាធិការប្រតិបត្តិខេត្ត សង្គមស៊ីវិល និងតុលាការ ។ យើងជ្រើសរើសមន្ត្រី បង្គោលនេះ គឺ ដើម្បីធ្វើការជាមួយប្រព័ន្ធដែលមានស្រាប់ទាំងអស់នេះ និងជាអ្នកទទួលព័ត៌មានពីថ្នាក់លើ ហើយចែករំលែកព័ត៌មានជាបន្តទៅថ្នាក់ក្រោម ។ ក្នុងពេលនោះដែរលោកបានមានប្រសាសន៍ថា ក្នុងការចែករំលែកព័ត៌មានឬក៏ការផ្លាស់ប្តូរព័ត៌មានតាមរយៈ Focal Point នេះ

យើងគួរធ្វើដូចម្តេចដើម្បីធ្វើការផ្លាស់ប្តូរព័ត៌មានអោយបានក្នុងរយៈ ពេល១ ឬ២ខែម្តងនោះ ។ លោកបានលើកជាសំណួរសួរថាតើក្នុងលក្ខណៈបែបណាដែលយើងជ្រើសរើសមន្ត្រីបង្គោល ហើយត្រូវចែករំលែកព័ត៌មានតាមវិធីណាដែរ ។ ក្រោយពីយើងជ្រើសរើសបានមន្ត្រីបង្គោលហើយនោះ តើយើងផ្តល់ ព័ត៌មានយ៉ាងដូចម្តេច ជាមួយកងរាជអាវុធហត្ថទាក់ទងទៅនឹងរឿងព្រហ្មទណ្ឌនោះ ? ។

លោក ម៉ក់ សំភារ នាយរងខុទ្ទកាល័យសាលាខេត្តសៀមរាបបានមានសំណួរថា ១-តើលក្ខណៈសម្បត្តិបែប ណា ? ២-តើតម្រូវការជ្រើសរើស ប៉ុន្មាននាក់ ? ៣-មានជំនាញបែបណា និង៤-មានមុខងារអ្វី ? ។

ព្រះរាជអាជ្ញាមានសំណួរសួរថា តើព័ត៌មានដែលត្រូវផ្តល់នោះជាព័ត៌មានដូចម្តេច ជាបទល្មើសឬជាព័ត៌មាន រដ្ឋបាល ? ។

លោកស្រី ជា សុខនាថ មេធាវី បានលើកឡើងពីលក្ខណៈសម្បត្តិសម្រាប់ជ្រើសរើសមន្ត្រីបង្គោល និងសួរថា តើយើងមានការបណ្តុះបណ្តាលដែរឬទេ ហើយតើស្ថាប័នណាជាអ្នកសម្របសម្រួល ?

លោក ជឿន ពៅ អភិបាលរងស្រុកសៀមរាប បានមានប្រសាសន៍ថានៅខេត្តសៀមរាប មានមណ្ឌលសេវា កម្មយុត្តិធម៌ថ្នាក់ស្រុកមានចំនួន ៦ ស្រុកហើយ ។ មន្ត្រីទាំងនោះមានប្រាក់ខែ ១៥០ដុល្លារ ហើយលេខាធិការមាន ប្រាក់ខែចំនួន៥០ដុល្លារ ប៉ុន្តែមកទល់នឹងពេលនេះមិនទាន់ឃើញមានមន្ត្រីសេវាកម្មយុត្តិធម៌ស្រុកមកធ្វើការអស់រយៈពេល ៦ ខែ មកហើយ មូលហេតុមកពីប្រាក់ខែមិនគ្រប់គ្រាន់ ហើយមន្ត្រីទាំងនោះសុទ្ធតែនៅឯទីក្រុងភ្នំពេញ ។

ហេតុដូច្នេះ លោកយល់ថាការជ្រើសរើសមន្ត្រីបង្គោលនេះ គួរមានការជ្រើសរើសនៅថ្នាក់មូលដ្ឋានតែម្តងទៅ ប៉ុន្តែតើយើងគួរជ្រើសរើសយកត្រឹមកំរឹតថ្នាក់ណា ត្រឹមបាក់ឌុប ឬយ៉ាងណា ? ។

លោក កៅ សោភ័ណ្ឌ អភិបាលស្រុកជីក្រែងខេត្តសៀមរាប បានមានប្រសាសន៍ថា ផ្អែកតាមគោល នយោបាយវិមជ្ឍការ និងវិសហមជ្ឍការ ទាក់ទងនឹងការជ្រើសរើសមន្ត្រីបង្គោលតាមបែបលក្ខណៈខ្វះថវិកានេះ តាម យោបល់ផ្ទាល់របស់លោក នៅថ្នាក់ខេត្តក៏ដូចជានៅថ្នាក់ស្រុកមានគណៈកម្មការប្រតិបត្តិដូច្នេះ យើងគួររើសមន្ត្រីដែល មានស្រាប់ដើម្បីជាមន្ត្រីបង្គោលស្រាប់ ។ លោកបានស្នើសុំផងដែរថា បើសិនជាដំណើរការទៅបាន គួរតែមានមន្ត្រី បង្គោលនៅថ្នាក់ស្រុកផងដែរ ដើម្បីអោយមានភាពងាយស្រួលក្នុងការចែករំលែកព័ត៌មាន និងមានចំណេះដឹងបន្ថែម ។

តំណាងមេធាវីម្នាក់បានមានសំណួរដែរថា ការជ្រើសរើសមន្ត្រីបង្គោល ថាតើយើងត្រូវជ្រើសរើសពីមន្ត្រីរបស់រដ្ឋ ដែលមានស្រាប់ឬក៏មានការជ្រើសរើសពីអង្គការដែរឬយ៉ាងណា ?

លោក ណុប វុទ្ធី LICADHO ប្រចាំខេត្តសៀមរាប បានចូលរួមយោបល់ថា ការជ្រើសរើសមន្ត្រីបង្គោល គួរមានសមាសសភាពដូចខាងក្រោម ៖

- មន្ត្រីមន្ទីរផ្សេងៗរបស់រដ្ឋាភិបាល
- ខាងសង្គមស៊ីវិលដែលបានបំពេញការងារទាក់ទងការកែទម្រង់នេះយ៉ាងច្រើន
- លោកបានបន្តទៀតថា តើយើងផ្តួចផ្តើមធ្វើការនៅកន្លែងណា ? តាមយោបល់របស់លោកផ្ទាល់លោកគិតថា គួរតែមានសហការពីខាងឯកឧត្តមខុទ្ទកាល័យខេត្តផងដែរ ថាតើគួរជ្រើសរើសធ្វើការនៅកន្លែងណា ?

ឯកឧត្តម សួង លាងហៃ បានធ្វើការបូកសរុបលទ្ធផលនៃការពិភាក្សា ។ ហើយបញ្ជាក់ជូនអង្គប្រជុំថានឹង ប្រមូលផ្តុំមតិយោបល់ល្អៗទាំងអស់របស់អង្គប្រជុំដើម្បីធ្វើសេចក្តីសម្រេចស្តីពីការចាត់តាំងមន្ត្រីបង្គោលនេះទៅក្នុង ពេលខាងមុខដ៏ឆាប់ៗ ។

ជាចុងក្រោយឯកឧត្តមប្រធានអង្គប្រជុំបានថ្លែងអំណរគុណជាថ្មីចំពោះឯកឧត្តមអភិបាលរងខេត្ត និងឯកឧត្តម អស់លោក លោកស្រីដែលជាប្រធាននិងមន្ត្រីមន្ទីរជំនាញជុំវិញខេត្តសៀមរាប ដែលបានចូលរួមក្នុងអង្គសិក្ខាសាលានា ថ្ងៃនេះ និងបានប្រសិទ្ធិពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ ជូនដល់អង្គសិក្ខាសាលាទាំងមូល ។

អង្គប្រជុំពិភាក្សាបានចប់សព្វគ្រប់នៅវេលាម៉ោងដប់មួយថ្ងៃត្រង់នាថ្ងៃដដែល ។

**បានឃើញ និងឯកភាព**
**នាយករងអង្គភាពគ្រប់គ្រងគម្រោង** **អ្នកធ្វើរបាយការណ៍**

សួង លាងហៃ សេង រ៉ាន់ដា ស៊ុន សិរីវុធ